**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១២៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី.
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## <u>ស ម្រេ ច</u>

**មាត្រា១.-**

ត្រូវបានដំឡើងថ្នាក់ស្មើមន្ទីរសុខាភិបាល ខេត្ត ក្រុង និងដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងសុខាភិបាល នូវសាលាមធ្យមសិក្សា សុខាភិបាលភូមិភាគទាំងបួន ដូចខាងក្រោម :

- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ បាត់ដំបង
- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ កំពង់ចាម
- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ កំពត

- សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ ស្ទឹងត្រែង ។

**មាត្រា២.-**

សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ ទាំងបួនខាងលើ មានបេសកកម្មបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែក ថែទាំវេជ្ជសាស្ត្រ និងអមវេជ្ជសាស្ត្រទាំងមូលដ្ឋាន ក្រោយមូលដ្ឋាន និងបន្ត ចាប់តាំងពីថ្នាក់ បឋម ដល់ថ្នាក់ មធ្យម ។

**មាត្រា៣.-**

សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ នីមួយៗ ដឹកនាំដោយ នាយកមួយរូប ថ្នាក់ស្មើ ប្រធានមន្ទីរ សុខាភិបាល ខេត្ត ក្រុង និង មាននាយករង មួយឬ ច្រើនរូប ថ្នាក់ស្មើអនុប្រធានមន្ទីរសុខាភិបាល ខេត្ត ក្រុង ជាជំនួយការ ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅ របស់សាលាមធ្យមសិក្សា សុខាភិបាលភូមិភាគ នីមួយៗ ត្រូវកំណត់ ដោយប្រកាសក្រសួងសុខាភិបាល ។

**មាត្រា៥.-**

បទប្បញ្ញត្តិ ទាំងឡាយណា ដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជា និរាករណ៍ ។

**មាត្រា៦.-**

រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សុខាភិបាល រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ មានភារៈកិច្ច អនុវត្ត អនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ហុង ស៊ុនហួត**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ